00644278

E46

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក ខៀវ សំផន

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ១៤ កុម្ភៈ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**:

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**អញ្ញត្រកម្មបឋមលើយុត្តាធិការ**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី ស ស្វ៊ាន

មេធាវី Jacques VERGÈS

មេធាវី Philippe GRÉCIANO

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ អូត្តារ៉ា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
14 / 02 / 2011
ម៉ោង (Time/Heure): 16:06
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU FORT

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## ១. រំឭកនីតិវិធី

១. កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានបញ្ជូនលោក ខៀវ សំផន ទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1] ដើម្បីវិនិច្ឆ័យទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងអំពើល្មើសនឹងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[2]។

## ២. សេចក្តីផ្តើម

២. ថ្ងៃនេះ លោក ខៀវ សំផន សូមដាក់អញ្ញត្រកម្មបឋមពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើវិធាន៨៩(១)(ក) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។ នៅថ្ងៃដដែលនេះ លោកបានដាក់អញ្ញត្រកម្មបឋមពាក់ព័ន្ធនឹងការរលត់បណ្តឹងអាជ្ញា ដោយយោងតាមមាត្រា ៨៩ (១) (ខ) នៃវិធានផ្ទៃក្នុង។ ដោយសារតែចំនួនទំព័រមានកម្រិត សំណើទាំងអស់នេះត្រូវបានដាក់ជាលក្ខណៈសង្ខេប។ លោក ខៀវ សំផន សូមរក្សាសិទ្ធិផ្តល់ខ្លឹមសារលម្អិតលើចំណុចទាំងអស់នេះនៅក្នុងសេចក្តីសន្និដ្ឋានបន្ថែម។

### ២.១ លក្ខណៈកូនកាត់របស់ អ.វ.ត.ក

៣. លក្ខណៈកូនកាត់របស់អ.វ.ត.ក ដែលថាអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូង និងតុលាការកំពូល"[3] តម្រូវឲ្យ អ.វ.ត.ក អនុវត្តច្បាប់ជាតិកម្ពុជា[4]។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ *ឯកសារតុលាការ* D427/4/14។

[2] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ *ឯកសារតុលាការ* D427 កថាខណ្ឌ១៦១៣។

[3] មាត្រា២ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[4] ផ្ទុយពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត អ.វ.ត.ក មិនត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬដោយសន្ធិសញ្ញាពហុភាគីនោះទេ។ ដូច្នេះ អ.វ.ត.ក មិនមែនជាតុលាការ

## ២.២ គោលការណ៍ទូទៅនៃច្បាប់

### ២.២.១ គោលការណ៍នីត្យានុកូលភាព៖ គ្មានបទល្មើស បើគ្មានច្បាប់ចែង និងគ្មានទោស បើគ្មានច្បាប់ចែង ( *nullum crimen sine lege, nullum poena sine lege* )

៤. គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស[5] គឺជាការធានាថាគ្មានបទល្មើស ឬទោសឡើយ ប្រសិនបើគ្មានច្បាប់ចែង[6]។ ច្បាប់ត្រូវកំណត់និយមន័យបទឧក្រិដ្ឋ និងកំណត់ទោសដែលត្រូវយកមកអនុវត្ត។ គោលការណ៍នេះផ្អែកលើប្រការថាច្បាប់ព្រហ្មទណ្ឌត្រូវមានលក្ខណៈអាចយល់បាន និងអាចដឹងមុនបាន។ ដូច្នេះ "រាល់អំពើផ្ទុយនឹងសណ្តាប់ធ្នាប់សង្គម ទោះជាមានកម្រិតធ្ងន់ធ្ងរប៉ុណ្ណាក៏ដោយ មិនមែនសុទ្ធតែតម្រូវឱ្យចារីប្រឈមមុខនឹងការដាក់ទណ្ឌកម្មខាងព្រហ្មទណ្ឌនោះឡើយ"។ ដើម្បីឱ្យអាចផ្តន្ទាទោសបាន អំពើនោះត្រូវដាក់ទោសដោយច្បាប់។ អាចចាត់ទុកថាជាបទល្មើសដែលអាចដាក់ទណ្ឌកម្មបាន តែអំពើទាំងឡាយណាដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ (បទឧក្រិដ្ឋ និងបទមជ្ឈិម) ឬដោយបទបញ្ជា (បទលហុ) ប៉ុណ្ណោះ។ ចាប់ពីពេលនេះតទៅ ចៅក្រមមិនអាចត្រូវបានអនុញ្ញាតឱ្យបកស្រាយបទប្បញ្ញត្តិដែលត្រូវដាក់ទណ្ឌកម្មខាងព្រហ្មទណ្ឌ ក្នុងន័យទូលាយឡើយ ពីព្រោះការបកស្រាយបែបនេះនឹងអនុញ្ញាតឱ្យចៅក្រមបង្កើតជាបទដ្ឋាន"[7]។ យោង

---

អន្តរជាតិឡើយ។ ច្បាប់ដែលត្រូវអនុវត្តនៅចំពោះមុខ អ.វ.ត.ក គឺរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២ (អនុវត្តនៅសម័យចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៦) រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ច្បាប់ព្រហ្មទណ្ឌទាំងឡាយដែលផ្តន្ទាទោសស្រាលជាងដែលបច្ចុប្បន្ននៅជាធរមាន និងជាយថាហេតុ ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមាននៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

[5] គោលការណ៍នេះត្រូវបានបញ្ជាក់ឡើងវិញដោយមាត្រា៨ នៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋឆ្នាំ១៧៨៩ មាត្រា១១ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៣៣(២) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ សូមមើលផងដែរ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ *ឯកសារតុលាការ* D427/3/1 កថាខណ្ឌ១២ ដល់កថាខណ្ឌ១៤។

[6] Bernard Bouloc *នីតិព្រហ្មទណ្ឌទូទៅ* គ្រឹះស្ថានបោះពុម្ពផ្សាយ Précis Dalloz បោះពុម្ពលើកទី២០ (ឆ្នាំ២០០៧) ទំព័រ១០១ និង១២៥។

[7] Bernard Bouloc *នីតិព្រហ្មទណ្ឌទូទៅ* គ្រឹះស្ថានបោះពុម្ពផ្សាយ Précis Dalloz បោះពុម្ពលើកទី២០ (ឆ្នាំ២០០៧) ទំព័រ១២៥។

តាមគោលការណ៍នេះ ក្រុមប្រឹក្សាធម្មនុញ្ញបារាំងបានរំឭកអំពីកាតព្វកិច្ចរបស់អ្នកធ្វើច្បាប់ ក្នុងការ "កំណត់ធាតុផ្សំនៃបទឧក្រិដ្ឋឱ្យបានច្បាស់ និងជាក់លាក់"[8]។

៥. ដូច្នេះ វាមិនទាន់គ្រប់គ្រាន់ទេ ដោយគ្រាន់តែបង្ហាញអំពីអត្ថិភាព នៃបទឧក្រិដ្ឋដែលបាន ប្រព្រឹត្តនៅសម័យកាលកើតហេតុនោះ តែច្បាប់ត្រូវកំណត់និយមន័យលម្អិតនៃបទឧក្រិដ្ឋ និងទោសដែលត្រូវយកមកអនុវត្តចំពោះបទឧក្រិដ្ឋនេះថែមទៀត។

**២.២.២ គោលការណ៍បកស្រាយតឹងរ៉ឹងនៃច្បាប់ព្រហ្មទណ្ឌ** ***(Poenalia sunt restringenda)***

៦. ច្បាប់ព្រហ្មទណ្ឌត្រូវតែបកស្រាយយ៉ាងតឹងរ៉ឹង។ មានតែច្បាប់ប៉ុណ្ណោះដែលមាន "សិទ្ធិរឹត ត្បិតសិទ្ធិសេរីភាពរបស់បុគ្គល ដោយហាមឃាត់អំពើមួយចំនួន ក្រោមការគំរាមកំហែង ដាក់ទោស។ ក្រោមលេសបកស្រាយ ចៅក្រមមិនអាចបន្ថែមទៅលើច្បាប់ និងផ្តន្ទាទោស ដោយទំនើងចិត្តចំពោះអំពើដែលនីតិនិពន្ធវិទូមិនបានចែងច្បាស់ និងដាក់ទណ្ឌកម្មឡើយ"[9]។

**២.២.៣ គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលផ្តន្ទាទោសធ្ងន់ជាង**[10]

៧. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនអាចបង្កើតបទល្មើសថ្មីៗ ហើយអនុវត្តជាប្រតិសកម្ម ចំពោះអំពើដែលត្រូវបានអះអាងថាបានប្រព្រឹត្តកាលពីសាមសិបឆ្នាំមុនឡើយ។

**២.២.៤ ការអនុវត្តគោលការណ៍ទាំងនេះក្នុងតុលាការអន្តរជាតិ**

៨. នៅក្នុងរបាយការណ៍របស់លោកផ្ញើជូនក្រុមប្រឹក្សាសន្តិសុខ ស្តីពីការបង្កើតតុលាការឧក្រិដ្ឋ កម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អគ្គលេខាធិការអង្គការសហប្រជាជាតិ បានរំឭកថា គោលការណ៍ *គ្មានច្បាប់ គឺគ្មានបទល្មើស* "តម្រូវឱ្យតុលាការអន្តរជាតិអនុវត្ត

---

[8] ក្រុមប្រឹក្សាធម្មនុញ្ញបារាំង សេចក្តីសម្រេចលេខ ៨៤-១៨៣ DC ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៨៥។

[9] Bernard Bouloc *នីតិព្រហ្មទណ្ឌទូទៅ* គ្រឹះស្ថានបោះពុម្ពផ្សាយ Précis Dalloz បោះពុម្ពលើកទី២០ (ឆ្នាំ២០០៧) ទំព័រ១២៦។

[10] មាត្រា៧២ នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

វិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលជាផ្នែកនៃច្បាប់ទំនៀមទម្លាប់ ដោយគ្មានការសង្ស័យ"[11]។

### ២.២.៥ ភាពមិនអាចយកមកអនុវត្តបានដោយផ្ទាល់នៃសន្ធិសញ្ញាអន្តរជាតិ

៩. យោងតាមច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា សន្ធិសញ្ញាអន្តរជាតិមិនអាចត្រូវបានយកមកអនុវត្តដោយផ្ទាល់ឡើយ។

### ២.៣ ការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ

១០. មាត្រា៣៨(១) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ កំណត់ "ទំនៀមទម្លាប់អន្តរជាតិថាជាភ័ស្តុតាងនៃការអនុវត្តទូទៅ ដែលត្រូវបានទទួលយកថាជាច្បាប់"។ ការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្លើយតបទៅនឹងវិធានបង្កើតតឹងរ៉ឹងបំផុត។ វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចមានអត្ថិភាពបាន ដរាបណាមានធាតុផ្សំពីរ៖ ការអនុវត្តរបស់រដ្ឋ (*usus*)[12] និងទស្សនៈច្បាប់ (*opinio juris sive necessatis*) [13]។ ហេតុដូច្នេះ អង្គជំនុំ

---

[11] របាយការណ៍អគ្គលេខាធិការ រៀបចំឡើងដោយអនុលោមតាមកថាខណ្ឌ២ នៃសេចក្តីសម្រេចលេខ៨០៨ (១៩៩៣) របស់ក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៣ ឯកសារ S/25704 កថាខណ្ឌ៣៤ (គូសបន្ទាត់បន្ថែម)។

[12] Jean-Marie Henckaerts ពន្យល់ថា៖ "ការអនុវត្តរបស់រដ្ឋត្រូវតែពិនិត្យលើទិដ្ឋភាពពីរ៖ ទីមួយ យើងត្រូវដឹងថាតើការអនុវត្តណាខ្លះដែលចូលរួមក្នុងការបង្កើតវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ការជ្រើសរើសការអនុវត្តរបស់រដ្ឋ) និងទីពីរ ត្រូវកំណត់ថាតើការអនុវត្តណាមួយពិតជាបានបង្កើតជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ការវាយតម្លៃពីការអនុវត្តរបស់រដ្ឋ) ដែរឬទេ។ (...) ទោះបីជាសេចក្តីសម្រេចរបស់តុលាការអន្តរជាតិជាប្រភពបន្ទាប់បន្សំនៃនីតិអន្តរជាតិក៏ដោយ ក៏សេចក្តីសម្រេចទាំងនោះមិនមែនជាការអនុវត្តរបស់រដ្ឋដែរ។ នេះសបញ្ជាក់ឱ្យឃើញថា ផ្ទុយពីតុលាការជាតិ តុលាការអន្តរជាតិមិនមែនជាស្ថាប័នរដ្ឋឡើយ"។ ការអនុវត្តរបស់រដ្ឋមិនអាចបង្កើតជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ ប្រសិនបើវាមានលក្ខណៈ "ស្មើរតែដូចគ្នា" "ដដែលៗ និងជាតំណាង"។ Jean-Marie Henckaerts ការសិក្សាអំពីច្បាប់មនុស្សធម៌-ទំនៀមទម្លាប់អន្តរជាតិ។ វិភាគទានដល់ការស្វែងយល់ និងការគោរពវិធានច្បាប់ក្នុងជម្លោះប្រដាប់អាវុធ ការបកប្រែអត្ថបទដើមសរសេរជាភាសាអង់គ្លេស ដែលត្រូវបានបោះពុម្ពផ្សាយក្រោមចំណងជើងថា « Study on International humanitarian law: A contribution to the understanding and respect for the rule of law in armed conflict » ភាគទី៨៧ លេខ៨៥៧ ខែមីនា ឆ្នាំ២០០៥ ទំព័រ១៧៥-២១២ នៃទស្សនាវដ្តីអន្តរជាតិ កាកបាទក្រហម ទំព័រ៥ នៃអត្ថបទជាភាសាបារាំង។ អត្ថបទភាសាបារាំងមាននៅ៖ http://www.africaunion.org/ root/ua/Conferences/Octobre/PA/31%20oct/Abstract%20French.pdf.

ជម្រះសាលាដំបូងមិនអាចផ្អែកតែទៅលើយុត្តិសាស្ត្ររបស់តុលាការពិសេស (*ad hoc*) ដើម្បីបង្ហាញអំពីអត្ថិភាពនៃវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ ដោយសារតុលាការ និងពិសេសទៅទៀត សេចក្តីសម្រេចរបស់តុលាការទាំងនេះ មិនទាន់កើតមាននៅឡើយ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

## ៣. យុត្តាធិការលើបុគ្គល

១១. មាត្រា១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានកម្រិតយុត្តាធិការរបស់ អ.វ.ត.ក ត្រឹមមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា។ ពាក្យ "មេដឹកនាំ" ត្រូវបានកំណត់និយមន័យថា៖ "ជាអ្នកដែលធានានូវការដឹកនាំប្រទេសមួយពិតប្រាកដ (មេដឹកនាំរដ្ឋ)"[14]។ សញ្ញាណនៃការដឹកនាំប្រទេសពិតប្រាកដ ទាមទារឱ្យយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវកម្រិតត្រឹមបុគ្គលទទួលបន្ទុកចេញ<u>សេចក្តីសម្រេចពិតប្រាកដជាក់ស្តែង និងប្រតិបត្តិ ក្នុងកម្រិតរដ្ឋាភិបាល</u> ដោយយោងទៅលើ<u>លក្ខណៈពិសេសនៃរដ្ឋធម្មនុញ្ញ</u>របស់របបនយោបាយដែលត្រូវបានចោទប្រកាន់។

១២. សហចៅក្រមស៊ើបអង្កេតអះអាងថា "គណៈអចិន្ត្រៃយ៍គឺជាអង្គការមួយដែលមានសមាជិកតិចជាងគណៈមជ្ឈិម។ អង្គការនេះមានសមាសភាពសុទ្ធតែជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា"[15]។ សហចៅក្រមស៊ើបអង្កេតក៏អះអាងផងដែរថា "ទោះបីជាមានភ័ស្តុតាងបញ្ជាក់យ៉ាងច្បាស់ថា ខៀវ សំផន **ពុំមែន**ជាសមាជិកផ្លូវការនៃគណៈអចិន្ត្រៃយ៍ក្នុងពេលបក្សកុម្មុយនីស្តកម្ពុជាកាន់អំណាចក្តី ក៏វា**ទំនង**ថា ខៀវ សំផន បានជួយ ឬចូល

---

[13] តុលាការយុត្តិធម៌អន្តរជាតិ ខ្ពង់រាបបាតសមុទ្រ (លីប៊ី/ម៉ាល់តា) សាលដីកា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៥ កម្រងឯកសារតុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៨៥ ទំព័រ២៩-៣០ កថាខណ្ឌ២៧៖ "ច្បាស់ណាស់ថា សារធាតុនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានស្វែងរកជាដំបូងនៅក្នុងការអនុវត្តពិតប្រាកដ និងច្បាប់របស់រដ្ឋ ទោះបីជាអនុសញ្ញាពហុភាគីអាចមានតួនាទីសំខាន់ក្នុងការកត់ត្រា និងកំណត់ ឬអភិវឌ្ឍវិធានដែលក្លាយមកពីទំនៀមទម្លាប់"។

[14] CORNU (G.) *វាក្យស័ព្ទច្បាប់* ទស្សនាវដ្តីសាកលវិទ្យាល័យបារាំង « Dirigeant, ante » ទំព័រ៣០៣ (ឧបសម្ព័ន្ធ)។

[15] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ *ឯកសារតុលាការ* D427 កថាខណ្ឌ៤១។

រួមចំណែកដល់ការងាររបស់គណៈអចិន្ត្រៃយ៍"[16]។ ការអះអាងនេះគឺខុសទាំងស្រុង និងគ្មានមូលដ្ឋានទាល់តែសោះ។ លោក ខៀវ សំផន មិនមែនស្ថិតនៅក្នុងចំណោម "មេដឹកនាំជាន់ខ្ពស់" នោះទេ ពីព្រោះថាក្នុងឋានៈជាប្រមុខរដ្ឋ **លោក ខៀវ សំផន មិនដឹកនាំប្រទេស ឬចូលរួមក្នុងកិច្ចការរបស់រដ្ឋាភិបាល ឬកិច្ចការផ្ទៃក្នុងឡើយ**។ អង្គជំនុំជម្រះសាលាដំបូងមិនអាចផ្សារភ្ជាប់មុខងារជាតំណាង និងមុខងារការទូត ទៅនឹងការចូលរួមចំណែកពិតប្រាកដរបស់គណៈអចិន្ត្រៃយ៍បានឡើយ។

១៣. នៅក្នុងរបាយការណ៍សម្រាប់ប្រទេសកម្ពុជា ក្រុមអ្នកជំនាញបានសន្និដ្ឋានថា ខ្លួន "មិនគិតថា ពាក្យ"មេដឹកនាំ"សំដៅដល់បុគ្គលទាំងអស់ដែលកាន់មុខតំណែងខ្ពស់នៅក្នុងរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ឬក៏បក្សកុម្មុយនីស្តកម្ពុជា នោះទេ។ បញ្ជីឈ្មោះឥស្សរជនជាន់ខ្ពស់របស់រដ្ឋាភិបាលនិងបក្ស មិនសុទ្ធតែដូចគ្នាទៅនឹងបញ្ជីឈ្មោះបុគ្គលដែលទទួលខុសត្រូវជាន់ខ្ពស់បំផុតចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សនោះឡើយ ប្រសិនបើឥស្សរជនជាន់ខ្ពស់មួយចំនួនរបស់រដ្ឋាភិបាល ប្រហែលជាមិនបានដឹងពីអ្វីដែលបានកើតឡើង និងមិនបានចូលរួមក្នុងការធ្វើសេចក្តីសម្រេច"[17] នោះទេ។ ក្រុមអ្នកជំនាញផ្តល់អនុសាសន៍ថា "តុលាការគួរកាត់សេចក្តីតែជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់ចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរបំផុត ទៅលើសិទ្ធិមនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ"[18]។

១៤. ជាចុងក្រោយ ការចរចាអស់រយៈពេលដ៏យូរ (ប្រាំមួយឆ្នាំ!) ដែលបានឈានទៅដល់ការបង្កើត អ.វ.ត.ក បានបង្ហាញយ៉ាងច្បាស់ថា អ្នកចរចាចាប់អារម្មណ៍តែទៅលើអ្នកធ្វើសេចក្តីសម្រេចផ្នែកនយោបាយ ដែលកាន់**អំណាចនីតិប្រតិបត្តិពិតប្រាកដ**ប៉ុណ្ណោះ។ ពាក្យពេចន៍ "មេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលជ្រើសរើសដោយអ្នកតាក់តែងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្លុះបញ្ចាំងនូវស្មារតី នៃកិច្ចព្រម

---

[16] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ *ឯកសារតុលាការ* D427 កថាខណ្ឌ៩៥។

[17] លិខិតតែមួយរបស់អគ្គលេខាធិការ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ផ្ញើជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ ឯកសារ A/53/850, S/1999/231 ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ១០៩។

[18] លិខិតតែមួយរបស់អគ្គលេខាធិការ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ផ្ញើជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ ឯកសារ A/53/850, S/1999/231 ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ១១០។

ព្រៀង។ អ.វ.ត.ក មិនមានសិទ្ធិពង្រីកយុត្តាធិការដោយខ្លួនឯងនោះឡើយ។ អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយអត្ថបទច្បាប់។ យោងតាមគោលការណ៍បែងចែកអំណាច អំណាចតុលាការមិនបង្កើតច្បាប់នោះឡើយ តែអនុវត្តច្បាប់។ ចាប់ពីពេលនេះទៅ តុលាការត្រូវតែអនុវត្តកិច្ចព្រមព្រៀងយ៉ាងម៉ឺងម៉ាត់ ឱ្យតែកិច្ចព្រមព្រៀងនេះមិនរំលោភគោលការណ៍នីត្យានុកូលភាព និងមិនប៉ះពាល់ដល់គោលការណ៍យុត្តិធម៌ និងស្វែងរកការពិត។

**ឋានៈរបស់ប្រធានគណៈប្រធានរដ្ឋ**

១៥. លោក ខៀវ សំផន គឺជាប្រធានគណៈប្រធានរដ្ឋ ជាមុខងារដែលមានចែងនៅក្នុងជំពូក៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ[19]។ ជំពូកអំពីគណៈប្រធានរដ្ឋស្ថិតនៅក្រោយគេបង្អស់ពាក់ព័ន្ធនឹងការរៀបចំអំណាច[20]។ លើសពីនេះទៅទៀត គណៈប្រធានរដ្ឋត្រូវ "គោរពតាមមាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជា" ដែលបង្ហាញអំពីអាណាព្យាបាលភាព និងភាពគ្មានស្វ័យភាពរបស់គាត់។ ជាចុងក្រោយ មានការកំណត់ថាគណៈប្រធានរដ្ឋត្រូវស្ថិតនៅក្រោមការឃ្លាំមើលពីសភាតំណាងប្រជាជនកម្ពុជា[21]។ ដូច្នេះ គណៈប្រធានរដ្ឋមិនមែនជាស្ថាប័នស្វយ័តនោះឡើយ។

**៤. យុត្តាធិការលើរឿងក្តី**

[19] មាត្រា១១ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥ ចែងថា "គណៈប្រធានរដ្ឋមានភារៈតំណាងឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យ នៅក្នុងប្រទេស និងក្រៅប្រទេស ក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងតាមច្បាប់ និងតាមមាគ៌ានយោបាយ របស់សភាតំណាងប្រជាជនកម្ពុជា។ គណៈប្រធានរដ្ឋមានសមាសភាពដូចតទៅ៖ ប្រធានមួយរូប អនុប្រធានទី១មួយរូប និងអនុប្រធានទី២មួយរូប" សូមមើលសៀវភៅរបស់ Raoul Jennar "ប្រជុំរដ្ឋធម្មនុញ្ញកម្ពុជា (១៩៥៣-១៩៩៣)" មជ្ឈមណ្ឌលឯកសារបារាំង ក្រុងប៉ារីស (១៩៩៤) ទំព័រ៦៩។

[20] ជំពូកអំពីគណៈប្រធានរដ្ឋស្ថិតនៅបន្ទាប់ពីអំណាចធ្វើច្បាប់ (ជំពូក៥) អង្គការអនុវត្តច្បាប់ (ជំពូក៦) និងតុលាការ (ជំពូក៧)។

[21] *គម្រោងសេចក្តីសម្រេចចិត្តរបស់អង្គប្រជុំសន្និបាតលើកទី១ ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦* នៅក្នុងឯកសារស្តីពីអង្គប្រជុំសន្និបាតលើកទី១ ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនកម្ពុជា ពីថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ឯកសារតុលាការ ១៣.១៣ ទំព័រ២០។ ឯកសារនេះសរសេរថា "សភាតំណាងប្រជាជនកម្ពុជាត្រូវបើកសន្និបាតពេញអង្គប្រចាំឆ្នាំមួយដងក្នុងមួយឆ្នាំ ដើម្បីពិភាក្សាមាគ៌ានយោបាយក្នុងប្រទេស និងក្រៅប្រទេសប្រចាំឆ្នាំ ហើយពិនិត្យតាមដានសកម្មភាពរបស់គណៈប្រធានរដ្ឋ"។

## ៤.១ គោលនយោបាយ

១៦. មិនមានវិធានណាមួយ ដែលបង្ហាញអំពីកាតព្វកិច្ចទូទៅក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិឡើយ[22] ហើយច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចបង្កើតវិធាននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដោយមិនរំលោភទៅលើគោលការណ៍នីត្យានុកូលភាពនោះទេ។ មេធាវីការពារក្តីមិនបដិសេធទេថា បទឧក្រិដ្ឋដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាបទឧក្រិដ្ឋតាមច្បាប់ព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ បទឧក្រិដ្ឋត្រូវតែកាត់សេចក្តីឱ្យស្របតាមនិយមន័យរបស់វានៅក្នុងច្បាប់ជាតិជាធរមាន។ យ៉ាងណាមិញ ឧទាហរណ៍ អំពើមនុស្សឃាតត្រូវបានច្បាប់ជាតិកំណត់ថាជាបទឧក្រិដ្ឋ ប៉ុន្តែមិនអាចត្រូវបានចាត់ទុកថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍នោះឡើយ ក្នុងករណីដែលបទល្មើសទាំងនេះមិនមានចែងដោយច្បាប់ជាតិជាធរមានក្នុងអម្លុងពេលនោះ។

១៧. សាស្ត្រាចារ្យ Antonio Cassese បានសរសេរថា៖ "ជាធម្មតា តុលាការជាតិមិនធ្វើការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិ ដោយផ្អែកតែលើច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ពោលគឺនៅពេលឧក្រិដ្ឋកម្មនោះត្រូវបានកំណត់តែនៅក្នុងអង្គច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ផ្ទុយទៅវិញ តុលាការជាតិត្រូវព្យាយាមទាមទារឱ្យមានការតាក់តែងច្បាប់ជាតិមួយដែលកំណត់អំពីឧក្រិដ្ឋកម្ម និងផ្តល់យុត្តាធិការដល់តុលាការជាតិដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មនោះ ឬប្រសិនបើសន្ធិសញ្ញាមួយពាក់ព័ន្ធនឹងចំណុចនេះត្រូវបានឱ្យសច្ចាប័នដោយរដ្ឋដែលតុលាការនោះតាំងនៅ តុលាការជាតិត្រូវព្យាយាមស្នើសុំការអនុម័តច្បាប់អនុវត្តន៍មួយ ដែលអាចឱ្យខ្លួនអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃសន្ធិសញ្ញានោះឱ្យបានពេញលេញ"[23]។ មូលហេតុគឺថា "គោលការណ៍ប្រទាក់គ្នាទាំងពីរនេះ គឺគោលការណ៍

---

[22] សាស្ត្រាចារ្យ Antonio Cassese *នីតិព្រហ្មទណ្ឌអន្តរជាតិ* (ទស្សនាវដ្តីសាកលវិទ្យាល័យ Oxford ឆ្នាំ២០០៣) ទំព័រ ៣០២។ "ក្រៅពីគ្មានវិធានទំនៀមទម្លាប់ជាទូទៅ យើងមិនអាចរកឃើញគោលការណ៍អន្តរជាតិទូទៅសម្រាប់សំអាងដើម្បីបញ្ជាក់ថាកាតព្វកិច្ចក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិបានលេចឡើងនៅក្នុងសហគមន៍អន្តរជាតិ"។ បកប្រែក្រៅផ្លូវការរបស់តុលាការ៖ សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក *ឯកសារតុលាការ* D240 កំណត់សម្គាល់ជើងទំព័រ៥៤។

[23] សាស្ត្រាចារ្យ Antonio Cassese *នីតិព្រហ្មទណ្ឌអន្តរជាតិ* (ទស្សនាវដ្តីសាកលវិទ្យាល័យ Oxford ឆ្នាំ២០០៣) ទំព័រ ៣០៣។ បកប្រែក្រៅផ្លូវការរបស់តុលាការ៖ សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់

នីត្យានុកូលភាព និងគោលការណ៍សច្ចភាពផ្លូវច្បាប់ ត្រូវបានចាត់ទុកជាទូទៅថាជាគោលការណ៍ជាសារវន្តនៅក្នុងច្បាប់ ដែលគោលការណ៍ទាំងនេះរាំងយ៉ាងមានប្រសិទ្ធភាពមិនឱ្យដាក់បញ្ចូលវិធានទំនៀមទម្លាប់មិនសរសេរជាលាយលក្ខណ៍អក្សរ ទៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិ ទោះជាតាមរយៈការបកស្រាយក៏ដោយ [...]។ អាស្រ័យហេតុនេះ ការអនុម័តច្បាប់អនុវត្តន៍មួយគឺជាបុរេលក្ខខណ្ឌជាសកល សម្រាប់រាល់ការអនុវត្តគោលការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងច្បាប់ជាតិ”[24]។

### ៤.២ សហឧក្រិដ្ឋកម្មរួម

១៨. នៅទីនេះ លោក ខៀវ សំផន សូមរំឭកឡើងវិញអំពីទឡ្ហីករណ៍ដែលលោកបានលើកឡើងនៅកថាខណ្ឌ១៥ ដល់កថាខណ្ឌ២៦ នៃឯកសារ D97/16/9[25] និងទឡ្ហីករណ៍ទាំងអស់ដែលលោក អៀង សារី បានលើកឡើងនៅក្នុងសំណើចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨[26]។

### ៤.៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

១៩. ទោះបីជាប្រទេសកម្ពុជាបានឱ្យសច្ចាប័នលើអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ក៏ដោយ តែប្រសិនបើគ្មានការសម្របតម្រូវនៅក្នុងច្បាប់ជាតិចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អ.វ.ត.ក មិនអាចប្រកាសថាខ្លួនមានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយមិនរំលោភទៅលើគោលការណ៍នីត្យានុកូលភាពនោះ

---

ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក *ឯកសារតុលាការ* D240 កំណត់សម្គាល់ជើងទំព័រ ៤៦។

[24] Simonetta Stirling-Zanda *ការកំណត់ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅតុលាការអឺរ៉ុប (បារាំង អ៊ីតាលី អាល្លឺម៉ង់ ហូល្លង់ អេស្ប៉ាញ ស្វីស)* គួអង្គមិនមែនរដ្ឋ និងច្បាប់អន្តរជាតិ ៣, ៦ (ឆ្នាំ២០០៤) ការបកប្រែក្រៅផ្លូវការរបស់តុលាការ៖ សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក *ឯកសារតុលាការ* D240 កំណត់សម្គាល់ជើងទំព័រ៤៧។

[25] ចម្លើយរបស់សហមេធាវីការពារក្តីលោក ខៀវ សំផន តបនឹងចម្លើយរួមរបស់សហព្រះរាជអាជ្ញាលើសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ *ឯកសារតុលាការ* D97/16/9។

[26] ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ *ឯកសារតុលាការ* D97។

ឡើយ។ អំពើប្រល័យពូជសាសន៍មិនត្រូវបានកំណត់ថាជាបទឧក្រិដ្ឋឡើយ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

២០. អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ មិនអាចត្រូវបានយកមកអនុវត្តដោយផ្ទាល់ នៅក្នុងច្បាប់ជាតិនោះទេ។ មាត្រា៥ នៃអនុសញ្ញានេះតម្រូវឲ្យភាគីទាំងឡាយ "ចាត់វិធានការណ៍ច្បាប់ចាំបាច់នានា តាមក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញរៀងៗខ្លួន ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ និងជាពិសេសដើម្បីស្វែងរកការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌនានាប្រកបដោយប្រសិទ្ធិភាពចំពោះ ពិរុទ្ធបុគ្គលដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬអំពើណាមួយទៀតដែលរៀបរាប់ក្នុងមាត្រា៣ នៃអនុសញ្ញាខាងលើ"[27]។ ប្រសិនបើគ្មានបទប្បញ្ញត្តិបែបនេះទេ អ.វ.ត.ក មិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានឡើយ។ ម្យ៉ាងវិញទៀត ការសិក្សាមួយដែលធ្វើឡើងដោយវិទ្យាស្ថាន Max Planck បានបង្ហាញថា "ក្នុងចំណោមប្រទេសទាំងអស់ (៣៥រដ្ឋ) គ្មានប្រទេសណាមួយអាចដាក់ទណ្ឌកម្មទៅលើជនប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយផ្អែកតែទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ។ ទោះជាតាមវិធីណាក៏ដោយ នៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិ ត្រូវតែមានបទប្បញ្ញត្តិមួយដែលអនុញ្ញាតឲ្យផ្តន្ទាទោសនៅចំពោះមុខតុលាការជាតិ"[28]។

២១. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់យុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងសហឧក្រិដ្ឋកម្មរួម នៅក្នុងក្របខ័ណ្ឌទម្រង់នៃការទទួលខុសត្រូវ អង្គជំនុំជម្រះសាលាដំបូងមិនអាចអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ចំពោះឧក្រិដ្ឋកម្មដែលចេតនាប្រព្រឹត្តស្ថិតនៅក្នុងធាតុផ្សំអត្តនោម័ត *(mens rea)* បានឡើយ។ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម គឺ "គោលបំណងឧក្រិដ្ឋរួមដើម្បីប្រព្រឹត្តបទល្មើស ដែលក្នុងនោះ ចារីម្នាក់

---

[27] អនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១។

[28] Helmut Kreicker *ការផ្តន្ទាទោសបទប្រល័យពូជសាសន៍ដោយតុលាការជាតិ តាមទស្សនៈវិស័យប្រៀបធៀប* ទស្សនាវដ្តីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ៥ (ឆ្នាំ២០០៥) ៣១៣-៣២៨ ទំព័រ៣២០។ បកប្រែក្រៅផ្លូវការរបស់តុលាការ៖ សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក *ឯកសារតុលាការ* D240 កថាខណ្ឌ២៨។

ក្នុងចំណោមចារីដទៃទៀតប្រព្រឹត្តបទល្មើសមួយ នៅក្រៅពីផែនការរួម ប៉ុន្តែជាផលវិបាកពីធម្មជាតិ និងអាចមើលឃើញជាមុននៃឥទ្ធិពលបង្កឡើយដោយគោលបំណងឧក្រិដ្ឋរួមនោះ”។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវនេះអាស្រ័យលើចេតនាដោយប្រយោល *(dolus eventualis)* ។ នៅក្នុងរឿងក្តី *Stakic* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានវិនិច្ឆ័យថា រដ្ឋអាជ្ញាយល់ច្រឡំរវាងទម្រង់នៃការទទួលខុសត្រូវ និង ឧក្រិដ្ឋកម្មផ្ទាល់។ ការយល់ច្រឡំរវាងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម និងអំពើប្រល័យពូជសាសន៍ មានឥទ្ធិពលលុបបំបាត់ចេតនាប្រព្រឹត្តបទល្មើសពិសេស រហូតធ្វើឲ្យវារលាយបាត់។ តុលាការបានសម្រេចថាដើម្បីអាចឲ្យគេនិយាយបានថាមានការ“ប្រព្រឹត្ត”អំពើប្រល័យពូជសាសន៍មួយបាន ដរាបណាធាតុផ្សំរបស់វា រួមទាំង**ចេតនាប្រព្រឹត្តបទល្មើសពិសេស** ត្រូវបានបំពេញ[29]។

### ៤.៤ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ៤.៤.១ ភាពមិនអាចអនុវត្តបាននៃយុត្តិសាស្ត្រមុនអំឡុងឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩

២២. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចលើនិយមន័យ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” នៅឆ្នាំ១៩៥៦។ តុលាការបានវិនិច្ឆ័យថា “ប្រសិនបើការផ្តន្ទាទោសម្ចាស់បណ្តឹងពីបទល្មើសនេះដោយឈរលើមូលដ្ឋានច្បាស់លាស់គ្រប់គ្រាន់ តុលាការមិនចាំបាច់ស្វែងរកនិយមន័យនោះទេ យោងទៅលើស្ថានភាពច្បាប់អន្តរជាតិទៅលើបញ្ហានេះនៅសម័យកាលពាក់ព័ន្ធ” ហើយបានប្រកាស អំពីភាពមិនអាចអនុវត្តបាននៃប្រភពនានាមុនពេលអង្គហេតុដែលបានចោទប្រកាន់ ក្នុងការកំណត់និយមន័យ“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” នៅឆ្នាំ១៩៥៦[30]។

---

[29] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Milomir Stakic សំណុំរឿងលេខ IT-97-24-T សាលក្រម ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៥៣០។

[30] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Korbely* *តទល់នឹងប្រទេសហុងគ្រី* ពាក្យបណ្តឹងលេខ៩១៧៤/០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ៧៩ “តុលាការធម្មនុញ្ញបានផ្អែកលើសាលដីកាចេញដោយតុលាការយុត្តិធម៌អន្តរជាតិ ក្នុងសំណុំរឿង *នីការ៉ាហ្គ័រ តទល់នឹងសហរដ្ឋអាមេរិក* និងបានយោងទៅលើមាត្រា៣រួម ដែលត្រូវបានលើកឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅក្នុងរបាយការណ៍ស្តីពីលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (កថាខណ្ឌ១៨ ខាងលើ)។ ក៏ប៉ុន្តែ តុលាការសង្កេតឃើញថាប្រភពឯកសារយោងទាំងពីរនេះកើតមានមុនអង្គហេតុដែលត្រូវបានចោទប្រកាន់”។ (គូសបន្ទាត់បន្ថែម)

## ៤.៤.២ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនបង្កើតច្បាប់ព្រហ្មទណ្ឌទេ

២៣. អង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាមិនមានចែងនូវបទប្បញ្ញត្តិណាមួយទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ ហើយប្រទេសកម្ពុជាក៏មិនមែនជាសមាជិកនៃសន្ធិសញ្ញាណាមួយទាក់ទងនឹងឧក្រិដ្ឋកម្មនេះដែរ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវការកំណត់ថាតើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀម ទម្លាប់អន្តរជាតិដែរឬទេ ក្នុងអំឡុងពេលខាងលើ"[31]។

២៤. ច្បាប់ទំនៀមទម្លាប់អន្តរជាតិព្យាយាមធ្វើឱ្យទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋប្រព្រឹត្តទៅបានល្អ[32] ហើយមិនអាចគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋមួយ និងប្រជាពលរដ្ឋ ដោយបង្កើតជាបទដ្ឋានច្បាប់ព្រហ្មទណ្ឌដែលអាចអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិបានឡើយ។ ក្នុងរឿងព្រហ្មទណ្ឌ ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិរំលោភលើគោលការណ៍នីត្យានុកូលភាព ដែលចែងថាបទឧក្រិដ្ឋ និងទោសដែលអនុវត្តចំពោះបទឧក្រិដ្ឋនោះ ត្រូវកើតមាននៅពេលប្រព្រឹត្ត។ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សាលាវិនិច្ឆ័យបារាំងបានគូសបញ្ជាក់ឡើងវិញអំពីគោលការណ៍នីត្យានុកូលភាពថា៖ "ទំនៀមទម្លាប់អន្តរជាតិមិនអាចរារាំងអវត្តមាននៃអត្ថបទច្បាប់ផ្តន្ទាទោស ក្រោមការកំណត់ប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានឡើយ"[33]។

## ៤.៤.៣ ភាពមិនច្បាស់លាស់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

[31] សាលក្រម ក្នុងសំណុំរឿង០០១ *ឯកសារតុលាការ* E188 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ២៨៤។

[32] សមាគមច្បាប់អន្តរជាតិ (សន្និសីទក្រុងឡុងដ៍ របាយការណ៍សន្និសីទលើកទី៦៣ ៩៣៦) *"វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាវិធានមួយដែលត្រូវបានបង្កើតឡើង និងគាំទ្រដោយការអនុវត្តជាប្រចាំ និងដូចៗគ្នារបស់រដ្ឋនានា និងតួអង្គផ្សេងទៀតនៃច្បាប់អន្តរជាតិ ឬដោយប៉ះពាល់ដល់ទំនាក់ទំនងច្បាប់អន្តរជាតិ ក្នុងកាលៈទេសៈ ដែលនាំឱ្យមានការរំពឹងទុកស្របច្បាប់នូវការប្រព្រឹត្តដូចគ្នានាពេលអនាគត"* លើកឡើងនៅក្នុង Karim Khan និង Rodney Dixon ការអនុវត្ត នីតិវិធី និងភស្តុតាងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ Archbold, London Sweet និង Maxwell (ឆ្នាំ២០០៥)។

[33] សាលាវិនិច្ឆ័យ (បារាំង) សភាព្រហ្មទណ្ឌ បណ្តឹងសាទុក្ខលេខ០២-៨០៧១៩ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣។

២៥. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចបង្កើតបទដ្ឋានច្បាប់ព្រហ្មទណ្ឌ អង្គជំនុំជម្រះសាលាដំបូងត្រូវមានបន្ទុកបង្ហាញអំពីអត្ថិភាពនៃវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាមរយៈការបង្ហាញអំពីការអនុវត្តរបស់រដ្ឋនិងទស្សនៈច្បាប់ ដែលមាននៅក្នុង អំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

២៦. ប្រការសាមញ្ញដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវកំណត់នៅក្នុងលក្ខន្តិកៈរបស់តុលាការក្រុងនូរ៉េមប៊ឺក និងតុលាការក្រុងតូក្យូ មិនអាចគ្រប់គ្រាន់ក្នុងការកំណត់អត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាំងពីឆ្នាំ១៩៤៥ នោះទេ[34]។ តុលាការទាំងពីរនេះមានយុត្តាធិការកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មឈ្លានពាន ("ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព")។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្ហាញថាគ្មានច្បាប់ ទំនៀមទម្លាប់អន្តរជាតិចំពោះការឈ្លានពានទេ[35]។ ប្រសិនបើយើងចាត់ទុកថាលក្ខន្តិកៈរបស់តុលាការយោធា ឆ្លុះបញ្ចាំងអំពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិការសន្និដ្ឋានថា គ្រាន់តែផ្នែកមួយនៃឧក្រិដ្ឋកម្មដែលបានកំណត់ដោយលក្ខន្តិកៈ ឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ ហាក់ដូចជាពិបាកយល់។

---

[34] សូមមើលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Dusko Tadic យោបល់ដោយឡែករបស់ចៅក្រម Abi-Saab ទៅលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងអញ្ញត្រកម្មនៃអសមត្ថកិច្ច ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ សំណុំរឿងលេខ IT-94-1 "ឧក្រិដ្ឋកម្ម [ឧក្រិដ្ឋកម្មដែលបង្កើតបានជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ] ត្រូវបានកំណត់ឡើង នៅក្នុងបរិបទវង្វេលចិត្តខ្លាំង នៅក្នុងអង្គជំនុំជម្រះថ្នាក់ផ្សេងៗ ដែលការបន្តរនូវការខ្ចើមរអើមបែបនេះអាចស្វែងរកមធ្យោបាយក្នុងការសម្តែងចេញតាមផ្លូវច្បាប់ ដោយវាយប្រហារទៅលើគ្រប់ទិដ្ឋភាព និងការអនុវត្តទាំងអស់ដែលត្រូវបានហាមឃាត់គ្រប់ផ្នែកទាំងអស់ និងដោយមធ្យោបាយច្បាប់ដែលអាចគិតឃើញ។ ប្រការនេះនាំទៅដល់ការកំណត់បទដ្ឋានដែលមិនសូវមានរចនាសម្ព័ន្ធត្រឹមត្រូវ និងកម្រិតត្រួតគ្នាខ្ពស់រវាងឧក្រិដ្ឋកម្មទាំងនេះ"។

[35] នៅឆ្នាំ១៩៩៨ រដ្ឋទាំងនោះមិនបានឈានទៅដល់ការព្រមព្រៀងគ្នាលើលក្ខន្តិកៈក្រុងរ៉ូមទេ ហើយកាលពីឆ្នាំ២០១០ ក្នុងសន្និសីទចុងក្រោយស្តីពីការពិនិត្យឡើងវិញលើលក្ខន្តិកៈក្រុងរ៉ូម រដ្ឋភាគីបានសម្រេចដោយមានការស្រុះស្រួលគ្នាថា យុត្តាធិការរបស់តុលាករព្រហ្មទណ្ឌអន្តរជាតិលើបទឧក្រិដ្ឋឈ្លានពាន ត្រូវបានកម្រិតត្រឹម "បទឧក្រិដ្ឋឈ្លានពានដែលបានប្រព្រឹត្តឡើងមួយឆ្នាំបន្ទាប់ពីការឱ្យសច្ចាប័ន ឬការការទទួលយកវិសោធនកម្ម ដោយរដ្ឋភាគីចំនួន៣០" មាត្រា១៥ ស្ទួនពីរ(២) នៃលក្ខន្តិកៈក្រុងរ៉ូម ដែលត្រូវបានអនុម័តដោយសេចក្តីសម្រេច RC/Rec.6 ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០។

២៧. ម្យ៉ាងវិញទៀត មាត្រា៩ នៃកិច្ចព្រមព្រៀងចែងថា អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ក៏ប៉ុន្តែ លក្ខន្តិកៈនេះបានក្លាយជាកម្មវត្ថុនៃការចរចាអស់រយៈពេលដ៏យូរ និងការព្រមព្រៀងគ្នាជាច្រើនរវាងរដ្ឋនានា[36]។ នៅពេលសន្និសីទត្រៀមរៀបចំលក្ខន្តិកៈទីក្រុងរ៉ូម គណៈកម្មាធិការពិសេសសម្រាប់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ បានគូសបញ្ជាក់ឲ្យដឹងថា "មិនមានអនុសញ្ញាណាមួយបានផ្តល់និយមន័យគតិយុត្តិ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងមានភាពច្បាស់លាស់គ្រប់គ្រាន់ ដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ"[37]។ យោងតាមគោលការណ៍អប្រតិសកម្ម តុលាការព្រហ្មទណ្ឌអន្តរជាតិបានជ្រើសរើសដោយចេតនាថា ខ្លួនមានយុត្តាធិការតែលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្រោយពេលលក្ខន្តិកៈចូលជាធរមានប៉ុណ្ណោះ[38] ហើយអនុញ្ញាតឲ្យរដ្ឋភាគីក្នុងការលើកពេលចូលជាធរមាននៃលក្ខន្តិកៈចំពោះរដ្ឋរបស់ខ្លួន សម្រាប់រយៈពេលប្រាំពីរឆ្នាំ(អាចបន្តបាន)[39]។

## ៤.៥ ការរំលោភយ៉ាងធ្ងន់ធ្ងរនៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩

### ៤.៥.១ ច្បាប់ជាធរមាន

២៨. នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៥៨ ប្រទេសកម្ពុជាបានឲ្យសច្ចាប័នលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ទាំងបួន។ ប្រទេសវៀតណាមបានឲ្យសច្ចាប័ន នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥៧។ អនុសញ្ញាក្រុងហ្សឺណែវមិនមានលក្ខណៈជាច្បាប់ព្រហ្មទណ្ឌអន្តរជាតិទេ គឺមានគោលបំណងរំឭកដល់រដ្ឋនានានូវកាតព្វកិច្ចរបស់ខ្លួន ក្នុងអំឡុងពេលកើតមានអរិភាព។

---

[36] គណៈកម្មការពិសេសសម្រាប់ការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៥ ឯកសារ A/AC.244/CRP.6/Add.3។ អាចរកមើលបាននៅអាសយដ្ឋាន៖ http://www.legal-tools.org/doc/449795/។

[37] *ដូចខាងលើ* កថាខណ្ឌ៧។

[38] មាត្រា១១ នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ចំពោះការពិភាក្សាពាក់ព័ន្ធនឹងគោលការណ៍អប្រតិសកម្ម នៅពេលចរចាអំពីលក្ខន្តិកៈក្រុងរ៉ូម សូមមើលសេចក្តីប្រកាសព័ត៌មាន *វាគ្មិននៅក្នុងគណៈកម្មការសម្រាប់ការបង្កើតតុលាការបានថ្លែងថាលក្ខន្តិកៈរបស់តុលាការអន្តរជាតិមិនត្រូវមានលក្ខណៈប្រតិសកម្ម* ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ L/2769 អាចរកមើលបាននៅអាសយដ្ឋាន៖ http://www.legal-tools.org/doc/8f3e43/។

[39] មាត្រា១២៤ នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

### ៤.៥.២ អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ

២៩. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានអះអាងថា "ជម្លោះប្រដាប់អាវុធអន្តរជាតិមួយដែលជាការប្រឈមមុខដាក់គ្នារវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ បានផ្ទុះឡើងសឹងតែភ្លាមៗ បន្ទាប់ពីកងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ជម្លោះប្រដាប់អាវុធនេះបានអូសបន្លាយយ៉ាងហោចណាស់ ដល់ពេលដែលកងទ័ពវៀតណាមបានវាយចូលដល់ទីក្រុងភ្នំពេញ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ និងនៅពេលក្រោយៗមកទៀត"[40]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា "ការវាយប្រយុទ្ធត្រូវបានផ្អាកជាច្រើនលើកច្រើនសារ"[41]។ ការតម្រូវឲ្យបង្ហាញឲ្យបានច្បាស់ និងមិនស្រពេចស្រពិលនូវអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ មានសារៈសំខាន់ណាស់ ដើម្បីអនុវត្តយុត្តាធិការរបស់ អ.វ.ត.ក។ អត្ថិភាព ឬនត្ថិភាពនៃ ជម្លោះប្រដាប់អាវុធនឹងអាចឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថាខ្លួនមានយុត្តាធិការ លើការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[42]។ ក្នុងន័យនេះ សូមកត់សម្គាល់ថាមិនមានសេចក្តីសម្រេចចិត្តណាមួយរបស់ក្រុមប្រឹក្សាសន្តិសុខ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធដូចបានអះអាងរវាងប្រទេសកម្ពុជា និងវៀតណាមនោះទេ។ សេចក្តីសម្រេចចិត្តដំបូងរបស់មហាសន្និបាតនៃអង្គការសហប្រជា-ជាតិ និយាយសំដៅទៅដល់ជម្លោះប្រដាប់អាវុធនៅប្រទេសកម្ពុជា នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៧៩ និង"ការអន្តរាគមប្រដាប់អាវុធរបស់កងកម្លាំងពីខាងក្រៅ (ប្រទេសវៀតណាម) ទៅក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា"[43]។

---

[40] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ *ឯកសារតុលាការ* D427 កថាខណ្ឌ១៥០។

[41] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ *ឯកសារតុលាការ* D427 កថាខណ្ឌ១៥១ និង១៥២។

[42] ជាក់ស្តែង ក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះបានបន្ថែម "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ" ទៅនឹងធាតុផ្សំនៃជំពូកស្តីពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ *ឯកសារតុលាការ* D427/4/14។

[43] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងឱកាសកិច្ចប្រជុំពេញអង្គលើកទី៦១ ស្តីពី *ស្ថានការណ៍នៅកម្ពុជា* ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៧៩ ឯកសារ A/RES/34/22។

### ៤.៥.៣ ទំនាក់ទំនងរវាងឧក្រិដ្ឋកម្ម និងជម្លោះប្រដាប់អាវុធ

៣០. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួនពិតជាមានយុត្តាធិការលើឧក្រិដ្ឋកម្មសង្គ្រាមមែននោះ លោក ខៀវ សំផន សូមរំឭកអំពីយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថា "អត្ថិភាពនៃជម្លោះប្រដាប់អាវុធ ឬការកាន់កាប់ និងភាពអាចអនុវត្តបាននៃច្បាប់មនុស្សធម៌អន្តរជាតិនៅលើដែនដី មិនគ្រប់គ្រាន់សម្រាប់បង្កើតយុត្តាធិការអន្តរជាតិលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរនីមួយៗ ដែលត្រូវបានប្រព្រឹត្តនៅលើដែនដីរបស់អតីតយូហ្គោស្លាវីនោះទេ។ ដើម្បីឱ្យឧក្រិដ្ឋកម្មមួយស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការអន្តរជាតិ ត្រូវតែរកឱ្យឃើញថាមានទំនាក់ទំនងគ្រប់គ្រាន់មួយរវាងបទល្មើសដែលបានចោទប្រកាន់ និងជម្លោះប្រដាប់អាវុធ ដែលទំនាក់ទំនងនេះធ្វើឱ្យច្បាប់មនុស្សធម៌អន្តរជាតិអាចត្រូវបានយកមកអនុវត្ត"[44]។

### ៤.៥.៤ ជាតិជនរងគ្រោះ

៣១. មានតែឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តចំពោះជនបរទេសប៉ុណ្ណោះ ទើបអាចត្រូវបានចាត់ទុកថាជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ៖ "អ្នកដែលទទួលបានការការពារដោយអនុសញ្ញា គឺជនទាំងឡាយណាដែលធ្លាក់ទៅក្រោមអំណាចរបស់ភាគីជម្លោះមួយ ឬមហាអំណាចកាន់កាប់**ដែលខ្លួនមិនមែនជាពលរដ្ឋ** នៅពេលណាមួយ និងទោះជាដោយរបៀបណាក៏ដោយ ក្នុងករណីជម្លោះ ឬកាន់កាប់"[45]។ ការប្រកាន់យកការបកស្រាយផ្សេងពីនេះ មិនត្រឹមតែដើរផ្ទុយទៅនឹងស្មារតីនៃអត្ថបទច្បាប់ (មាត្រា៣១ នៃអនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា) និងឆន្ទៈរបស់ភាគីនៃអនុសញ្ញាប៉ុណ្ណោះទេ ថែមទាំងផ្ទុយ ទៅនឹងគោលបំណងនៃអនុសញ្ញាអន្តរជាតិ ទៀតផង (មាត្រា៣២ នៃអនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា)។

---

[44] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Tadic* សំណុំរឿង IT-94-1-T សាលក្រម ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៥៧២។

[45] មាត្រា៤ នៃអនុសញ្ញា (៤) ក្រុងហ្សឺណែវស្តីពីការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

00644296



៣២. លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបញ្ចូលទៅក្នុង "ប្រភេទឧក្រិដ្ឋកម្មមួយដោយឡែក នៅក្នុងលក្ខន្តិកៈតុលាការយោធាអន្តរជាតិក្រុងនូរ៉ែមប៊ឺក (...) ដើម្បីកុំឱ្យអំពើរបស់ចារីប្រឆាំងនឹងប្រជាជាតិខ្លួនឯងអាចគេចផុតពីការចោទប្រកាន់ដោយតុលាការនេះ ទោះបីជាចារីប្រឆាំងនឹងប្រជាជាតិខ្លួនឯងមិនអាចនឹងត្រូវបានចោទប្រកាន់ បើអនុលោមតាមទម្រង់ទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ"[46]។ ការយល់ឃើញថាឧក្រិដ្ឋកម្មសង្គ្រាមអាចត្រូវបានប្រព្រឹត្តប្រឆាំងនឹង "ប្រជាជាតិឯង" បង្កើតឱ្យមានការយល់ច្រឡំរវាងនិយមន័យនៃឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គ្មានជនជាប់ចោទណាម្នាក់អាចត្រូវបានវិនិច្ឆ័យទោសពីរដងចំពោះអំពើល្មើសដូចគ្នានោះទេ។ មានតែការកំណត់ប្រភេទបទល្មើសព្រហ្មទណ្ឌខ្ពស់ជាងគេបំផុតប៉ុណ្ណោះ អាចត្រូវបានប្រកាន់យក។ ការសំអាងហេតុនេះមានភាពអនុលោមទៅនឹងមាត្រា១៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[47]។

## សេចក្តីសន្និដ្ឋាន

៣៣. អញ្ញត្រកម្មបឋមមានបំណងកំណត់យុត្តាធិការនៃអង្គជំនុំជម្រះ មុននឹងចាប់ផ្តើមសវនាការ។ លោក ខៀវ សំផន មានសិទ្ធិទទួលបានព័ត៌មានអំពីការដាក់បន្ទុកប្រឆាំងនឹងរូបលោក[48] ហើយមានសិទ្ធិមានពេលវេលា និងការបង្កភាពងាយស្រួលចាំបាច់ដល់ការរៀបចំការពាររូបលោក[49]។ នៅក្នុងករណីដែលលោកមានថិរវេលាខ្លីពេកសម្រាប់ដាក់សារណារបស់លោក (៣០ថ្ងៃបន្ទាប់ពីពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរ) ពុំមានអ្វីដែលបញ្ជាក់ថា អង្គ ជំនុំជម្រះអាចលើកចម្លើយរបស់ខ្លួនទៅពេលក្រោយ គឺនៅពេលសម្រេចទៅលើសាលក្រម នោះឡើយ។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង បានប្រកាស

---

[46] សាលក្រម សំណុំរឿង០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ០១០ *ឯកសារតុលាការ* E188 កថាខណ្ឌ២៨៥។

[47] ក្រមនេះមិនបានទទួលស្គាល់ពីពហុភាពនៃបទល្មើស "នៅពេលដែលអង្គហេតុតែមួយដូចគ្នាជាកម្មវត្ថុនៃការកំណត់ប្រភេទបទល្មើសព្រហ្មទណ្ឌផ្សេងៗជាច្រើន នៅក្នុងលក្ខខណ្ឌដែលបទល្មើសតែមួយអាចត្រូវផ្តន្ទាទោសច្រើនដង"។

[48] មាត្រា ៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[49] មាត្រា ១៤(៣) (ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា៣៣ ថ្មី ច្បាប់ឆ្នាំ២០០៤ ស្តីពីការបង្កើត អ.វ.ត.ក ។

លើអញ្ញត្រកម្ម បឋមស្តីពីការរលត់បណ្តឹងអាជ្ញា ដែលលើកឡើងដោយ កាំង ហ្កេកអ៊ាវ ហៅឌុច នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ គឺថានៅទន្ទឹមនឹងពេលដែលការវិនិច្ឆ័យទៅលើអង្គសេចក្តី (ស្របតាមវិធាន ៨៩ (៣) នៃវិធានផ្ទៃក្នុង)[50]។ លោក ខៀវ សំផន លើកឡើងថា ការលើកពេលបែបនេះប៉ះពាល់ដល់ការពិភាក្សាលើអង្គសេចក្តី។ ប្រសិនបើអង្គជំនុំជម្រះបានប្រកាស "ពីការរាំងស្ទះដល់ការបន្តធ្វើបណ្តឹងអាជ្ញាប្រឆាំងនឹងជនជាប់ចោទចំពោះបទល្មើសនៅក្នុងច្បាប់ជាតិ" មុនបើកសវនាការមែននោះ ម្ល៉េះសមអង្គជំនុំជម្រះអាចផ្តោតការយកចិត្តទុកដាក់ ទៅលើបន្ទុកផ្សេងទៀតលើជនជាប់ចោទជាមិនខាន។ លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះមេត្តាឆ្លើយទៅនឹងអញ្ញត្រកម្មបឋមដែលលើកឡើងមុនសវនាការបឋម ព្រោះលោកចង់បាននូវភាពច្បាស់លាស់ និងគុណភាពនៃការពិភាក្សា។

## **អាស្រ័យហេតុនេះ**

៣៧. មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

- **ប្រកាសថា** ពាក្យបណ្តឹងនេះអាចទទួលយកបានតាមទម្រង់ និងគតិច្បាប់
- **កត់សម្គាល់ថា** លោក ខៀវ សំផន គឺជាអតីតប្រធានគណៈប្រធានរដ្ឋទីពីរ បន្តវេនដោយផ្ទាល់ពី សម្តេច នរោត្តម សីហនុ ហើយក្នុងឋានៈនេះលោកមិនមែនជាអ្នកធ្វើសេចក្តីសម្រេចខាងផ្នែកនយោបាយទេ គឺគ្រាន់តែតំណាងឲ្យរដ្ឋ គ្មានអំណាចពិតប្រាកដ និងគ្មានអំណាចប្រតិបត្តិការឡើយ
- **ប្រកាសថា** អង្គជំនុំជម្រះសាលាដំបូងគ្មានយុត្តាធិការលើឋានៈបុគ្គលចំពោះរូបលោក ខៀវ សំផន ដែលជាប្រធានរដ្ឋត្រូវបានគេជ្រើសតាំង និងបន្តវេនដោយផ្ទាល់ ដូចសម្តេច នរោត្តម សីហនុ ដែលជាប្រធានរដ្ឋទីមួយរបស់ខ្មែរក្រហម នោះឡើយ

---

[50] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសក្នុងច្បាប់ជាតិដែលលើកឡើងដោយមេធាវីការពារក្តី ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារតុលាការ E187 កថាខណ្ឌទី៥៦ ។

- **ប្រកាសថា** អង្គជំនុំជម្រះសាលាដំបូងគ្មានយុត្តាធិការលើរឿងក្តីចំពោះបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ឡើយ
- **ចេញសេចក្តីសម្រេច** មុនពេលបើកកិច្ចដំណើរការជំនុំជម្រះក្តី។

**រក្សាសិទ្ធិគ្រប់យ៉ាង និងដើម្បីយុត្តិធម៌**

មេធាវី ស ស្វាន មេធាវី Jacques VERGÈS មេធាវី Philippe GRÉCIANO